**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

GTI GRAND TWINS

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល**
**(ខេមបូឌា) ភីអិលស៊ី**

*ថ្ងៃ ពុធ ២ កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី ៣៥ អាណត្តិទី២ របស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ចាប់ពីម៉ោង ៩:០០ ព្រឹក នៅទីស្នាក់ការក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ("**ក្រុមហ៊ុន**") ដែលមានទីតាំងនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា តាមរយៈការប្រជុំពីចម្ងាយ (Virtual Meeting) លោក **Yang Shaw Shin** ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី ៣៥ របស់ក្រុមហ៊ុន។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៣៥ អាណត្តិទី២ នេះ អង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងផុសផុលលើខ្លឹមសារលម្អិតនៃរបាយការណ៍ប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលទទួលបានលទ្ធផល និងអនុម័ត ដូចខាងក្រោម៖

១. ការធ្លាក់ចុះនៃការបញ្ជាទិញពីអតិថិជនចម្បងរបស់ក្រុមហ៊ុន Adidas ក្នុងឆ្នាំ ២០២១ និងការបញ្ចប់នៃការបញ្ជាទិញ នៅខែមិថុនា ឆ្នាំ ២០២២
២. ការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី ៨ របស់ក្រុមហ៊ុន
៣. ផែនការបែងចែកភាគលាភជូនភាគហ៊ុនិក និងអភិបាលរបស់ក្រុមហ៊ុនសម្រាប់ឆ្នាំ ២០២២
៤. ការបោះឆ្នោតជ្រើសរើសអភិបាល និងអភិបាលឯករាជ្យរបស់ក្រុមហ៊ុន
៥. ការលាលែងពីតំណែងរបសើបុគ្គលិកជាន់ខ្ពស់ និងការជ្រើសរើសបេក្ខភាពថ្មីរបស់ក្រុមហ៊ុន
៦. ការផ្ទេរកម្មសិទ្ធនៃអគារ Gateway ជាមួយក្រសួង និងភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធនានា
៧. ការពង្រឹងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុន រួមទាំងការបង្កើតគោលនយោបាយនានា
៨. បញ្ហាផ្សេងៗ

អង្គប្រជុំបានបញ្ចប់ទៅនៅវេលាម៉ោង ១១:៣០ ព្រឹក នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

**ក្រុមហ៊ុន គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី**